00285361

Declassified to Public
06 September 2012



+5

# របាយការណ៍សរុបរបស់ មន្ទីរ ស-២១

## I.– អំពី ផែនការរួមចុងក្រោយ

**ក.– សំនាំដើម.–**

១.– សរុបតាមចម្លើយ ឈូក លេខាតំបន់២៤ ដែលយើងធ្វើសរុបថ្ងៃ 23 កញ្ញា 1976 និងចម្លើយសរសេរ ផ្ទាល់ដៃរបស់ គាត់ខ្លួនលើកទី 19 ថ្ងៃ 23 កញ្ញា 1976 ដែរ ។ គឺសរុបតាមចម្លើយនេះធ្វើជា មូលដ្ឋាន ។

២.– ចម្លើយ អ៊ីសុប គន្ធី ខាងក្រសួងការបរទេស ក៏មានលក្ខណៈប្រហាក់ប្រហែលគ្នា ត្រង់បញ្ហា វាយលុកពីក្រៅ និង ការស៊ុមគ្រលំគ្នា រវាង យួន សូវៀត លាវ សៀម ចក្រពត្តិអាមេរិក ។

៣.– [redacted] ។

ដូចនេះ យើងធ្វើតាម សរុបថ្មី ដូចតទៅ ៖

**ខ.– ខ្លឹមសារសរុប.–**

១.– សូវៀតជាក្បាលម៉ាស៊ីននៃផែនការក្បត់នៅកម្ពុជា ។ វាយក យួន ជាអ្នកអនុវត្តផ្ទាល់ ។ ⊕

២.– ចក្រពត្តិអាមេរិក វាស៊ុមគ្រលំជាមួយ សូវៀត ដោយជំរុញ សៀម ឲ្យខ្នងផ្ដើមសង្គ្រប់ដល់ ពួកខ្មែរសេរី នៅប្រទេសថៃ ។

៣.– ក្នុងប្រទេស ពួកភ្នាក់ងារ សេអ៊ីអា និង យួនលេបទឹកដី ជាពិសេស, វាសហការគ្នា អនុវត្ត ផែនការ តែមួយ ហើយដែលវាទាក់ទងជាប់ជាមួយខាងក្រៅប្រទេស ។

ទ្រ. ឈូក វាទាក់ទងទៅបៃម៉ិប ។

ពួក យួន ទាក់ទងទៅយួនដង ដែលពិសេសទាក់ទងទៅថៃ តាមរយៈ សុត លេខា តំបន់ 106 និង ពួក ហាយ ទៅតាមពួក ។

ពួក សាយ ទាក់ទង ទៅថៃផ្ទាល់ ។

ពួក ហង់ 103 វាទាក់ទងទៅថៃដែរ ទៅយួន តាមរយៈ លាវដែរ ។

---

⊕ លាវ វាចេញមុខថែម រួមដៃជាមួយ យួន ក្នុងករណីចាំបាច់ ។

## ៤.- ផែនទីនិងដំណើរការ.-

១- សិទ្ធ គឺវាដំណើរការសម្លាប់ ដោយ លួចឆ្លៀតឱកាស ឬ លួចចាប់ អ.ប.ក ក្នុងពិធីបុណ្យ ឬពេលធ្វើដំណើរ ។ល។

បើសំរេច គឺ ពួកវា ផ្លាស់ប្តូរ ការដាក់គំនាប ក្នុងប្រទេស ដោយឆ្លៀតឱកាស⊕ ។ ស្មើសាធារណ មតិច្រូលច្របល់ ក្នុងប្រទេស និង ក្នុង សកលលោក ។

២- ក្នុងករណីទីមួយ មិនបានសំរេច គឺពួកវា បំផុស ពាក្យចចាមអារាម វិទ្ធង្សនកម្ម បាតុកម្ម ដើម្បី ហើយ ឈានទៅកុប្បកម្មតាមផ្នែកៗ ។

ឧ. បំផុស ចាមខេត្ត ឆ្លៀតដំណឹងដំរើ ចាមនយសន្តិសុខ ទៅខាងកំពង់សោម

ឧ. ពួក ជក្រី ធ្វើកន្ទ្រប់បែកក្រោយវាំង បាញ់នៅលោកដា ដើមឆ្នាំ 1976

ឧ. ផែនការ របស់ពួក ហ៊ឹម និង ពៅ ក្រ នៅតំបន់ 37 ភូមិភាគបស្ចិម និងរបស់ពួកស្រេង នៅ ភូមិភាគ កណ្តាល [redacted] ។

ឧ. បាតុកម្ម នៅស្រុកមុខកំពូល ខែ 11. 75 ។

៣- ក្នុងករណីទីពីរនេះ មិនសំរេចទៀត គឺ ទ័ព យួន និង ទ័ពក្បត់នៅក្រៅកម្ពុជា និងវាយចេញ លុកចូលពីក្រៅមកពីរទិសខាងកើតលិច ។ វាយបណ្តើរ ពាក់សំបកឈ្លានពានបណ្តើរៗ ។

- វាយលុករហ័ស ហើយដកចេញរហ័ស ។ យកវត្ថុ. នៅអង្គការ និង ជេក្ខស្លាក់ ។ ធ្វើយ៉ាងនេះ ដើម្បី ការពារ មតិ សកលលោក ។
- បើមិនសំរេចតាមស្រួលទេ គឺវាយក គ្រឿង ទាំងកើតទន្លេមេគង្គ ដោយប្រកាស យកទឹកដី ស្វាយរៀង ជា ជាតិ រួចហើយបន្តការវាយដណ្តើមតាមស្រួលទៀត ។
- តែបើបរាជ័យតាមស្រួល គឺ មួយផ្នែក បែកមុខមាត់ ត្រូវរត់ទៅក្រៅប្រទេស និងមួយផ្នែកទៀត មិនទាន់បែកមុខមាត់ ត្រូវបង្កប់លាក់ខ្លួនបន្តទៀត ក្នុង ប.ក.ក ។

៤- សំណូមពររបស់វា បើមិនសំរេចអ្វីទេ យ៉ាងហោចណាស់ ក៏បានត្រឹមរាំងរាំង អុកឡុក និង បំផ្លាញ សេដ្ឋកិច្ច ពន្យឺតដំណើរការប្រទេសរបស់ បដិវត្តន៍យើងដែរ ។

---

⊕ តាមស្របបញ្ជាប់ យកប្រភាព ជាឡើងគ្រួរ ហើយ ចាប់យាត់ខ្លួន ឬ តាមកុប្បកម្ម ដោយផ្ញើក្បត់នៅកន្លែងនិមួយៗធ្វើឬ តាមរយៈការប្រមូលទ័ពវាយប្រយុទ្ធ តែម្តង ។ ផ្លូវនេះ គឺទៅតាមសភាពជាក់ស្តែង ។

00285363



## II.- អំពី ខ្សែសង្វាក់ចាត់តាំង និង ការកសាងកម្លាំង របស់ ភ្នាក់ងារ សេអ៊ីអា និង យួនលេបទឹកដី.

①.- ពួកវាយករូបភាពស្របច្បាប់ ក្នុងការចាត់តាំងភ្នាក់ងារវា ដើម្បីផ្តើមផ្តួលរំលំរដ្ឋអំណាចបដិវត្ត ហើយវាយកឋានៈនាទីក្នុងបក្ស ក្នុងរដ្ឋអំណាច ដើម្បីធ្វើសកម្មភាពក្បត់ផង ដើម្បីការពារបក្សពួកវា ដែលធ្វើសកម្មភាពនៅត្រូវបែកធ្លាយមាត់ផង ។

ឧទា. មូលដ្ឋានតំបន់ 24 និង កងពល 170 គឺពួក ឈូក ចក្រី ធ្វើយ៉ាងនេះ

ឧទា. ខ្សែពួក កុយធួន អតីតលេខាភូមិភាគឧត្តរ ក៏វាធ្វើយ៉ាងនេះដែរ ។

ដូចនេះ ធ្វើឲ្យតែការលាក់ ដាក់ខ្លួនកន្លែងទៅ កន្លែងណាដែលពួកវាកាន់កាប់ត្រាំត្រែងយូរ ហើយ គឺកន្លែងនោះ ខ្សែក្បត់គឺអនេកដាច់ដោយៗ ។

②.- ប្រភេទកម្លាំង ដែលពួកវាប្រមូលផ្តុំបាន គឺគ្រប់កម្លាំងទាំងអស់ដែលទំនាស់ តិច - ច្រើន ជាមួយ ប.ក.ក ខាង~~[illegible]~~ ឈរជើង សមូហភាព ខាងស្មូនគ្រប់ប្រភេទ ។ល។

ឧទា. លក្ខន្តិកៈបក្សពលករ ដែលដាច់ឡើយរឿងដី លោកនេត ខាងនឹកដល់ពួនទៅសូរភូមិភាគបូព៌ា ( ឯកសារ ថ្ងៃ 9.7.1977)

③.- <u>អំពីវិធីដំណើរការ</u>.-

ក.- <u>សម័យមុនថ្ងៃ 18.3.70</u> ពួកវាមានវិធានការក្តាប់នាទីដឹកនាំ ដើម្បីមានសិទ្ធិដក កម្មាភិបាលបដិវត្ត ឬបាត់បង់សកម្មភាពក្បត់ផ្សេងៗ ។

សកម្មភាពមួយ ក្នុងចំណោមសកម្មភាពដទៃទៀត គឺពួកវាសហការជាមួយវណ្ណៈកាន់អំណាច ដោយឲ្យពត៌មានទៅវណ្ណៈកាន់អំណាច ឲ្យចាប់កម្មាភិបាលបដិវត្ត ឬលបធ្វើឃាត ។

ឧទា. សុផានវាថា ឈូកបានឲ្យគិញចាប់វាគឺ យកមកដាក់គុក ដើម្បីធាត់ថែង ការងារនៅតំបន់ 24 បានស្រួល ។ ឈ្មោះវាក់នេះ ក្រោយ 17.4.75 មកនៅក្រសួងការបរទេស ។

ឧទា. ពួកកែវមាស ស៊ា ផ្តើមក្តាប់ក្រុមប្រជាជន និងបញ្ចូលពួកវិញអ៊ន ៧ ក្តាប់សាលាកម្មបុគ្គ ។

ឧទា. ស្រេង កាត់ទៅលើហ្វាយស្រុកព្រៃឈរ ឈ្មោះ ស.ហុក ឲ្យកត្តាតមូលដ្ឋានបក្ស

ហើយ វាប្រមូលកម្លាំងបាក់ស្មារតី កសាងឲ្យក្បត់បដិវត្ត ។

3គ. ពួកវាឃោសនាឲ្យមើលឃើញកម្លាំងខ្លាំងខ្លួន មើលឃើញបដិវត្តសំពុកវេទនាយូរអង្វែង ហើយ កុំនឹងកោះ កុំនឹងត្រើយទេ ។ ត្រូវដើរដើងលើ ខាងណាឈ្នះ នៅតាមខាងណោះ ។ នេះជាវិធីឃោសនា របស់ សេអ៊ីអា ។

ចំណែកវិធីឃោសនារបស់ភ្នាក់ងារយួនវិញ គឺវាឃោសនា[redacted] ឲ្យគាំទ្រជំនួយបរទេស 3គ. ជា បង្កើតឲ្យតពួក[redacted] ទៅរៀននៅយួន និងត្រឡប់មកវិញ ហើយ គេនេះបណ្តុះពេលគ្រប់អ្នក , ជាកងទ័ពយួនរួមរំដោះ ជំយួនគេវាយឡើង ជំនួយយើង ឃើញអត់អីយើងទេ: កុំនឹងវាយឡូវនៃ យើងមិនកើតទេ ។

ខ.- សម័យសង្គ្រាម 5 ឆ្នាំ រំដោះប្រទេស.-

1. ពួកវា មានវិធានការ ក្តាប់ កងទ័ព ជាសំខាន់បំផុត ។

   3គ. ពួក កយថួន ក៏យ៉ាងនេះ ពួក ឈុក ពួក ឃុំ ក៏យ៉ាងនេះ

2. ពួកវា ប្រើ សិទ្ធិអំណាច ក្រុមភិបាលបដិវត្តស្រេចនឹងចិត្ត តាមវិស័យចោរប្រកាន់ផ្សេងៗជាដើម , ជំរុញឲ្យក្ដាប់ ៤ លួចស៊ីយាជ ក្នុងសមរភូមិដើម ។ នេះជំពោះទីណា ដែល កម្លាំងក្បត់ វាក្តោបក្តាប់បានតាមស្រួល ។ ដូចពួកវា ប្រមូល សមាសភាពមិនល្អ ជា ចោរបាស់ ជាតិញ គលាន ពួកពាលា បញ្ចូលមកក្នុង កងទ័ព មកក្នុងមន្ទីរ ... ។

3. ពួកវា ត្រៀមលក្ខណៈសម្បត្តិសព្វគ្រប់ សំរាប់ដណ្តើម អំណាច ក្រោយ ពួក លន់ណុល ដួល ។

គ.- សម័យការពារប្រទេស

1. ពួកវាឆ្លៀតឱកាស ពេលអង្គការ ស៊ីកម្មភិបាលផ្សេងៗ បញ្ជូនភ្នាក់ងារវា មក ។

   3គ. ពួកជក្រៃ បញ្ជូនកម្លាំងវា មកពន្លហោះ មកកាំភ្លើងធំ ។ល។

   3គ. ពួក ឈួន មកក្ដាប់ ក្រសួងពាណិជ្ជកម្មរដ្ឋ

2. ពួកវា បំផុស ការជ្រៀតជ្រាក់ និងមូលដ្ឋានសុញ្ញសក្តិ 3គ. ធ្វើបដិវត្តយូរហើយ នៅតែជាយុទ្ធជន - បំភិតបំភ័យ អំពីបងប្អូនដាប់សមាសភាព - មិនអប់រំតាំ ដល់យុទ្ធជន ។ល។ ហើយអូសទាញឲ្យ[redacted]ក្បត់ ។

## ៤.- សរុបរឿងក្បត់ គិតជាភាគរយ

### ក.- មូលដ្ឋានក្បត់បដិវត្ត មុនថ្ងៃ 18.3.70

១- ក្រុមប្រជាជន : មាន កែវមាស , យ៉ា , ធនឃួន ជាមេក្លោង ។ វាប្រមូលបានពួកអតីតពុទ្ធិកបាលមួយចំនួន ដូចជា ឈូក លេខាតំបន់ ៥, ហង់ លេខាតំបន់ 103 , ញឹក លេខាតំបន់ 37 , សុវិបុតជីវិន តំបន់ ២៥ ។ កែវមាស (ពួកវាហៅបងអាចារ្យ) មានតួនាទីគ្រប់គ្រងដណ្តប់លើពួកវាលះណាស់។ ធាតុពិតរបស់ពួកវា ជាកញ្ចុះយួន ។ អ្វីៗរបស់យួន គឺប្រសើរអស់ ។

២. ពួកអតីតតស៊ូ ទៅរៀនទៅហាណូយ : មាន ស៊ីម ផឹកមិញ ម៉ីឆូ ហៅយ៉ែត កែវមុនី ជាមេក្លោង ។ ធាតុពិតរបស់ពួកនេះ គឺ មួយរយភាគរយ ទៅជាយួនទៅហើយ ។ វាលែងនៅជាខ្មែរទៀតហើយ គឺជាភ្នាក់ងារ ជាដៃរបស់ បក្សយួន ។

៣. ពួកខ្មែរសេរី ឬប្រជាចលនា :* ពួកនេះ នៅអាក់អាកាយគ្រប់កន្លែង តែសំខាន់ មានការគ្រប់គ្រងរបស់សេអ៊ឹម ជាប់លាប់រហូត ។

1 - មួយផ្នែក នៅ យួនខាងត្បូង និងនៅសៀម ដឹកនាំដោយ ស៊ឺងង៉ុកថាញ់

2 - មួយផ្នែកនៅក្នុងប្រទេស ដឹកនាំដោយ ហង់ធុនហាក់ [illegible] ។ ផ្នែកនេះ ចែកជាពីរទៀត ៖

- ផ្នែកដែលបែកមុខ (ហង់ធុនហាក់ ខាងរដ្ឋការ និង ទៀវជុំ ជីងវាក់ ខាងលោកសង្ឃ) រស់នៅក្នុងរដ្ឋការសីហនុ ។
- ផ្នែកដែលមិនទាន់បែកមុខ គឺចូលបង្កប់ក្នុងជួរបដិវត្ត តាមការចាត់តាំង របស់ហង់ធុនហាក់ ជាលម្អាក់ គឺ ខ្មែររបស់ ទីមុល ដែលក្នុងនេះមាន កុយធួន អតីតលេខា 304 និងកម្លាំងកណ្តាលជំនាន់ក្រោយៗទៀតដូចជា វ៉ែកគីមហួត , ឆែកប៉ែន , ជាហួន , សាន , ហ៊ង់ នៅខាងពោយញ៉ែ , សារិន នៅ ខាងតំបន់ 33 ជាដើម ។

ខ្មែររបស់ទៀវជុំ មាន អាចារ្យ វ៉ើន នៅវត្តកំពង់ , អាចារ្យ ហាយហ៊ិល (ពួកចក្រ) នៅវត្តស្ទឹងស្លូត ។

---

* ពួកនេះ វាប្រមូលកម្លាំង តាមការឃោសនា រំដោះកម្ពុជាក្រោម ។ ក្រៅពីនេះ ពួកវាជាឃ្លាំ គឺឃោសនាតាមរូបភាពបដិវត្តទាំងអស់ ពិសេសគឺនៅទីណា ដែលពួកវាបែកមុខនៅក្នុងមហាជន ។

៣ – មួយផ្នែក ដែលជាប់ជិតស្និទ្ធជាមួយ បក្សពួកក្បត់រហូត គឺ ខៀវ វិញ គិញ នៅ
វត្តខ្មែរក្រោម ។ ពួកនេះ មានចំណាស់ជាងគេ ។ វិញ គិញ ជាមេដឹកនាំ ដូច
ស៊ីង ស៊ុកចាញ់ដែរ ក្នុងចំណោម មេធំៗ របស់ខ្មែរសេរី ចំរុះ ។

សមាសភាព ភាគច្រើន គឺប្រមូល អ្នកមកពីកម្ពុជាក្រោម ។

ពួកនេះ ក៏ចែកជា ពីរផ្នែក ដែរ ។

- មួយផ្នែក ទៅនៅជាមួយ ឈៀកកុង ដូចវិញ គិញ ដែរ ។
- មួយផ្នែក យ៉ា គ្រប់គ្រង ចូលបង្កប់ក្នុង ប.ក.ក ដូចជា លីឆែង កេចញ្ញ កង នៅដំរី សុផាន នៅ 170 ។
- មួយផ្នែកទៀត ចូលបង្កប់ក្នុងចំណោម ពួកទៅរៀនទៅហាណូយ មាន ស៊ីនតារ៉ៃ ហៅ ស្រេង , ស៊ីនសុវ៉ាត , [redacted] ។

៤ – មួយផ្នែក ជាខ្មែររបស់ ស៊ីង ស៊ុកចាញ់ នៅប្រទេសបារាំង ហើយដែលចូលបង្កប់
ទៅជាមួយ ពួកទៅរៀន ទៅហាណូយដែរ គឺមាន ភាគសាមឿន ហៅរស់
និង ហ៊ាងណារិន ហៅភាគ ។

ជំហរវិភាគរបស់ ពួកទៅរៀនទៅហាណូយ និង ពួក ដៃវមាស ចំពោះ ចលនារបស់ពួកខ្មែរសេរី មួយប្រជាគ
តាមចម្លើយរបស់ ស៊ីនតារ៉ៃ ហៅ ស្រេង និង តាមចម្លើយរបស់ ឈ្មួកលោភតំបន់ 44⊕ ៖

គឺតាំងពីមុនសន្និសីទ ហ្សឺណែវ ម្ល៉េះ ពួកអតីតតស៊ូ ដែលពិភាក្សាគ្នាហូរហែ ថា ចលនា
របស់ ស៊ីង ស៊ុកចាញ់ ជាចលនាស្នេហាជាតិមួយដែរ ។ ពួកវា មានចិត្តប្រមូលពួកនេះ រួម
ជាកម្លាំងជាប់ជានិច្ច ។ ពួកវាម្នាក់ៗ ជិតជាមជំហរវិភាគបែបនេះរៀងរហូតមក បានជាដាក់ឱ្យរួមពិ

ឧគ. ស៊ីនតារ៉ៃ ក្នុងការទាក់ទងជាមួយ ហ៊ាងណារិន តាមការរៀបរាប់របស់វិញ គិញ
ក៏វាសរសេរដាក់ក្នុងប្រវត្តិរូប ថា មានធ្លាប់ទាក់ទងជាមួយ ស៊ីង ស៊ុកចាញ់ ។ តាមរយៈ
នេះ ហ៊ាងណារិន ក៏យល់ដឹងទៅបញ្ហា ។

ឧគ. ពួកឈ្មួក សហការ ជាមួយខ្មែរសេរី នៅវៃ , វិញ គិញ ក្នុងនាម បក្សពួកអ៊ីប
ពួកកូនចៅ ស៊ីង ស៊ុកចាញ់ មកគ្រប់គ្រង ក្រោយ 17.4.75 ដើម្បី យកកម្លាំងនេះ
រួមដៃ វាយ ប.ក.ក ។

ឧគ. នន សួន ដើម្បីរស់ជង ក៏ព្រមចូលសេអ៊ីអា ទៅក្នុងគុក ។ នេះតាមចម្លើយ
របស់ តាម៉ុំ ឌួន ។

---

⊕ – ប៊ុនតារី ក្នុងចម្លើយតាម៉ុំ ក៏មាននិយាយ អំពី ស្បែរ: ដំហរវិភាគ របស់ពួកទៅរៀននេះដែរ ដូចជា
រ៉ូ ស៊ីនស៊ុកមិញ ដែរគុធឹ ។ល។

៥- ពួកអាណិកជនចិន ៈ- ពួកនេះ មានប្រភពទៅពីពួក កុកមិនតាំង តាមរយៈពួកចិនរត់មកពីប្រទេសចិន ។
[illegible] ពួកនេះមានចំណាស់យូរណាស់ហើយ គឺមុនឆ្នាំ 1944 ទៅទៀត ។
អង្គការសមាគមផ្សេងៗ សាលាចិន ពេទ្យចិន គឺសុទ្ធសឹងតែពួក កុកមិនតាំង កាន់ក្តាប់ គ្រប់គ្រង បញ្ជា ។
មុនឆ្នាំ 1956 គឺមុនសីហនុ ចាក់ចំណងការទូតជាមួយចិនប្រជាមានិត ពួកនេះ លើកទង់ពួក ថៅកាយ ក្រោក ដាក់ហ៊ា ។ តែ
ក្រោយឆ្នាំ 1956 សីហនុ ក៏ហាមឃាត់ ពួកនេះ ក៏បែរមកជាសម្ងាត់ ហើយធ្វើសកម្មភាព លាក់ខ្លួនបន្តទៀត ។

ពួកទាំងនេះភ្ជាប់ជាមួយ ពួកសេអ៊ីអេ យួន ទេះជាសំខាន់ ជាមួយនោះក៏វាធ្វើជាចោរលួចលួចចិន ដើម្បីជលប្រយោជន៍
សេដ្ឋកិច្ចរបស់ពួកវាផង ។ ការទទួលការណែនាំសំខាន់ គឺពី តៃវ៉ាន់ តាមរយៈ ហុងកុង ។

សមាជិករបស់ កុកមិនតាំង ក្រោយមកក្លាយជាសេអ៊ីអា ដោយភាគច្រើនដាច់ខាត ។ ឧទាហរណ៍ដូចជា
ខ្មៅ ក្នុង ខែ 2 ឆ្នាំ 3 . 1976 ដែលពួកវាកំពុងរៀបចំផែនការ វាយបក្សនៅថ្ងៃ 17.4.76 ក្នុងក្រុងភ្នំពេញ
វាយបុកលើកទី ២ ។

មូលដ្ឋានធំៗរបស់ពួកនេះ មាននៅភ្នំពេញ ដូចជា ផ្សារ អូឡាំពិក ដើមគរ និងពេទ្យចិនជាដើម ។ នៅ
ខេត្ត គឺមានតាមខេត្តនានា ដូចជា កំពត បាត់ដំបង សៀមរាប កំពង់ចាម ។ល។

ឥឡូវនេះ គឺ អូឡាំពិក ។ ការនេះ ជាការពិត ។ តាមហេតុ ភ្នំពេញ ត្រូវដែលបានចាត់ចែងខ្សែនេះ ។ ពួកវា
[illegible] ពីពួក មកពី ហ៊ុងកុង ដែលពួកវាបានបង្កើតនៅគ្រប់ការណាស់ហើយ ។

៤. ពួកបញ្ជូនជន : ពួកនេះជាពួករួមរស់ជាមួយវៀតណាម សីហនុ ។ ពួកខ្លះធ្លាប់ជាវៀត
ណា តែក្រោយស្លាប់ ក៏ធ្លាក់ខ្លួនទៅ • ពួកខ្លះជាសេអ៊ីអា ធ្វើជាវៀត
ចូលបង្កប់ក្នុង ប.វ. ដើម្បីយកការណ៍ខ្មែរ ។
ពួកនេះ មាន គួងសឿន ហ៊ុចវ៉ៃន មីនាត់ ហ៊ួយទ ហ៊ួនឹម [redacted]
ហ៊ំ អតីតលេខាតំបន់ 15 និង លេខាតំបន់ 22 សុក ក្រូច សោម ទៅ
សេនាធិការ ជាដើម ។ បញ្ជូនទៅវៀតណាមវិញ ក្នុងខែ 10 ឆ្នាំ 1977 មក ។
គោលដៅ របស់ពួកនេះ គឺជាភ្នាក់ងារ សេអ៊ីអា សុទ្ធសាធ ។

៥. ពួកនាយទាហាន ជាសេអ៊ីអា ដែលគេរៀនទៅ ស.រ.អា ហើយត្រូវឲ្យបញ្ជាឲ្យចូលមក
នៅក្រោយពេលរំដោះ 17 មេសា 75 ភ្លាម
យកការណ៍ អំពីបដិវត្តកម្ពុជា តាមប្រភព ផ្ទៃ រោគ្យនិវត្តន៍ មានពួក ស្គន់ ដាញ់ សត្តិ
ស៊ុម ស៊ីឡុណា អ៊ុង ពើងហួ ជាដើម ។
បេសកកម្ម របស់ពួកនេះ គឺចូលមករកគាំទ្រ ក្រុមស្ដាំ - ននស្ដាំ - សោកនាយ -
ចេងសាយ៉ុមប៊ិន (តាមឃើញកំពុង ដូចមាន បរិសិន និង ល៉ាង ដែរ) ។

៦. ពួក នាយទុន ដួច ចុង អតីតអនុលេខាភូមិភាគនិរតី ជាសេអ៊ីអា ចូលបង្កប់ សម័យ
មុនឆ្នាំ 1954 ។ គាត់នេះ ជាជនជាតិ យួន នៅកោះកុង ។ គេឃើញពីឆ្នាំ 1974 ។

៧. ពួកនិស្សិតទៅរៀននៅបរទេស ហើយដែលនិយម សូវៀត .. ពួកនេះ ជាភ្នាក់ងារ
កាសេប ដែលចូលមកក្នុងប្រទេស ដើម្បីរួមដៃជាមួយ ពួកភ្នាក់ងារយួន ។
កន្លងមក វាមានបាត់តែង បក្សមួយ នៅឆ្នាំ 1965 ដែលមាន ហាក់ស៊ាងឡាយនី
ជាលេខា បក្សកុម្មុយនីស្តខ្មែរ ។ តែពួកវាធ្វើការមិនកើត ។
ពួកនេះមាននៅច្រើនប្រទេសដែរ ដូចជា ពួក ហាក់ស៊ាងឡាយនី នៅសូវៀត ,
ពួក ទូច ខាំឌឿន នៅបារាំង , អ៊ាងប៊ី នៅចេក
តែពួកនេះ មួយចំនែក ក៏ចូលជា សេអ៊ីអា ដែរ ដោយវណ្ណៈការពារអំណាច ក្បែរស្បែក
ខ្លួន ដូចជា អៀងសីហា អ៊ាងប៊ី ជាដើម ។
បញ្ជូនទៅវៀតណាមវិញ ក្នុងឆ្នាំ 1977

៨. ក្រៅពីនេះ ក៏មានភ្នាក់ងារប្រទេសផ្សេងៗទៀត ដូចជា សាទនា (SDECE បារាំង)
ប៊ុនណានី អតីតតស៊ូ ភ្នាក់ងារបារាំងចាំការទៅស៊ូ , ... FDGB អាល្លឺម៉ង់ខាងកើត

---

• ពេលប.វ.មានអំណាច ពួកវាក៏សុំក្នុងទៅ ឈ្លើម ថានៈនាទី

១.- មូលដ្ឋានក្បត់បដិវត្ត ដែលខ្មែរក្បត់កសាងបានដូចក្រោមនេះ

១.- ខ្សែ ចុង អនុលេខាភូមិភាគបស្ចិម

1. តំបន់ 11 បោសសំអាតឆ្នាំ 1976

2. តំបន់ 37 ញ៉ឹក បោសសំអាតដើមឆ្នាំ 1977 : គណៈស្រុក 100%

២.- ខ្សែ សំរិទ្ធ ហៅ ហុន លេខាតំបន់ 33 ភាគនិរតី បោសសំអាតដើមឆ្នាំ 1975

៣.- ខ្សែនន់សួន ហៅ ជ័យ លេខាតំបន់ 25 ភាគនិរតី បោសសំអាតពីចុងឆ្នាំ 1975 មក
ពាត-សន-សៀន នៅកងពល 703 – ចិរិន, ហួតសេ, សុក នៅតំបន់ 25

៤.- ខ្សែ ហំ - ខែក - នៅ គណៈតំបន់ 15 ភាគបស្ចិម បោសសំអាតដើមឆ្នាំ 1976

៥. ខ្សែ កប, កណ្ដុរ, ពឹម របស់អាចាបវឺន តំបន់ 31 ភាគបស្ចិម បោសសំអាតពីដើមឆ្នាំ 1976 មក ។

៦.- ខ្សែ ឈូក - ចក្រី នៅតំបន់ 24 និងកងពល 170 បោសសំអាតនៅខែ 4.1976 និងខែ 8.1976 ។ ក្រៅពីនេះមានពួកលីហ៊ែន លេខាធិការ, ម៉ៃដូ អនុតំ.21

៧.- ខ្សែ កុយធួន អតីតលេខាភូមិភាគឧត្តរ បោសសំអាតពីថ្ងៃ 17.2.1977 មក

1 – កងពលអ/ក 310-450-920 (ថ្នាក់វ.ត 100% និងថ្នាក់អង្គភាពខ្លះ) កងវរ[illegible]

2 – ភូមិភាគ 304 និងកងពល 117 (ថ្នាក់ស្រុក និងថ្នាក់វ.ត ស្ទើរតែ 100%)

3 – តំបន់ 106 និងកងពល 335 (ថ្នាក់ឃុំ និងថ្នាក់វ.ត ស្ទើរតែ 100%)

4 – អតីតក្រសួងពាណិជ្ជកម្មរដ្ឋ

5 – តំបន់ 505 អាកង អនុលេខាតំបន់

6 – តំបន់ 105 ម៉ី, ខាំភួន គណៈតំបន់

៨.- ខ្សែ សាយ សមាជិកភូមិភាគពាយព្យ (រស់ម៉ើ ហៅ សាយ) បោសសំអាតពីខែ 6.1977 មក

1. កងពលភាគពាយព្យ : ការ, នៅ, វ៉ន្ត (នងសារ៉ែម ហៅ ការ) គណៈកងពល

2. តំបន់ 1 : ដាហ្វូន : ហ៊ាញ លេខា

3. តំបន់ 5 : ហ៊ែនស៊ុន : ហ៊ីង លេខា

៤- កែ សំបូរ ហៅ សុត ហៅម៉ុន លេខាតំបន់ 7

៥- តំបន់ 4 : កែ ប៉ែន ហៅ ស៊ូ អនុ ត. 4

6. ត. 6 : ម៉ុម ញឿន ហៅ ម៉ៃ សមាជិក ត.

៩. ខ្សែ ទុំ លេខាតំបន់ 22 ចាប់សំអាតពីខែ 4.1977 មក

1. តំបន់ 22 , គណៈតំបន់ - ស្រុក 100%

2. កងពល 152 របស់ម/ក ថ្នាក់ វ.ធំ វ.ត អធំ 100%

១០.- ខ្សែ យ៉ា

១១.- ខ្សែ ហង់ លេខាតំបន់ 103 ចាប់សំអាតពីខែ 1.1978 មក

១២- ក្រសួងឃោសនា របស់ អង្គការ

ទូច ភឿន ហៅ ភីន លេខាក្រសួងសាធារណការ ចាប់សំអាត ថ្ងៃ 17.2.77

ហ៊ុ នឹម ហៅ ភាស់ លេខាក្រសួងវិទ្យុ ចាប់សំអាតពីថ្ងៃ 10.4.1977

ស៊ិន ផាភា ហៅ សុក អតីតលេខាក្រុង , អតីតលេខាអគ្គីសនី ចាប់សំអាត 7.3.77

១៣- ខ្សែពួកកសិកដ្ឋាន ចាប់សំអាតពីខែ 2.1978 មក

ស៊ិន ហៅ ហុង ប្រធានកសិកដ្ឋាន

កុ មិន នៅក្រសួង ... ចំណេះពីប្រទេស គម្ពីរដំណាក់ម.ន.ម.

សុ ផា ហៅ ស នៅកសិដ្ឋាន ..

ខៀវ គណៈឧស្សាហកម្ម

ពួកមេធំៗ របស់ពួកវាដែលនៅសល់ ពេលៗ មាន :

③ ចំពោះ ពួក កុកមិនតាំង

មុនឆ្នាំ 1944 មានតែបក្សកុកមិនតាំងមួយគត់ ។ តែក្រោយជប៉ុនចាញ់ 1944 ពួកអាណាព្យាបាល
ក៏បង្កើតអង្គការដែលបែកចេញ ទៅជាបក្ស មួយទៀត មួយទៀត ។

នៅកម្ពុជា មុនឆ្នាំ 1956 ពួកគេ ស្ថិតនៅជាជំពូក តែក្រោយមក ដែលសីហនុ កាត់ទំនាក់ ពួក
នេះ ធ្វើសកម្មភាព ពាក់ព្ធ័ន បង្កើតអង្គការ ។ 1958 ... ។
តែដោយត្រូវ នៅក្រោម ជិន ពួកនេះ លើកយុទ្ធសាស្ត្រ បង្កប់ តាំងពីក្រោយឆ្នាំ 1963 ដែល
... ប.ក.ជ កាន់កាប់ប្រទេសចិនទាំងមូល ។
ស្នើ ... ទី IV ... ។

## III.– អំពីបញ្ហាបង្កប់ស៊ីរ៉ូងក្នុង ប.ក.ក និងការបំភ្លៃមាគ៌ា ប.ក.ក

### ក.– បញ្ហាបង្កប់ស៊ីរ៉ូងយួនអន្តិត

១.– អំពីកំណើតនៃផែនការបង្កប់នេះ :– ① ចម្លើយរបស់ ស៊ឹនសារី ហៅ ប៉ែវ ដែលយើងកត់សរុបថ្ងៃ 16.5.76 បានបញ្ជាក់ថា ពីឆ្នាំ 1952 ដល់ 1954 វៀតមិញ ធ្លើងចុះ ភ្នំដងរែក ប្រជុំសឹងសុីកចាត់ ដោយខ្លួនផ្ទាល់ក៏មាន ដោយប្រើសំពោកក៏មាន ។ អាកប្បកិរិយារបស់វៀតមិញ គឺបង្កើតឲ្យគេហៅ ស.ង.ខ ណាស់ ដែរយៈពេលក្រោយ គ្រប់តែមានប្រតិកម្មវាយប្រហារ ស.ង.ខ ជាមួយនោះ ក៏បាត់តាំង ស៊ឹនសារី និង ស៊ឹនសុវត្ថិ ឲ្យចូលបង្កប់ក្នុងឃ្យោតមិញ ក្នុងឆ្នាំ 1954 ដោយរៀបចំឈ្មោះឲ្យពីរនាក់នេះ ទៅកាត់ទង ភក់តាមឿន និង ហាំងណាវ អតីតនិស្សិតស្រុកទ្រាំង ដែលជាខ្មាំងរបស់ ស.ង.ខ ។

តាមរយៈនេះ បញ្ជាក់ថា សេអ៊ុក មានផែនការនេះ តាំងពីដំបូង ភក់តាមឿន និង ហាំងណាវ ចូលឃ្យោតមិញ ប្រមុនពេលនេះផង ។

② ចំពោះ យួន ... ក្រោយសន្និសិទហ្សឺណែវ អតីតតម្រួតម្នាក់ជំនួសទៅរៀនហាណូយ ជាំណែក ... ស៊ឹមសាត នៅជាមិត្ត ទទួលភារៈផ្ញើសំបុត្រពីយួនទៅផ្ទៃ មកគាត់ទង ដែរមាន នៅភ្នំពេញ ។ តាំងបុត្រក៏មាន តាំងចៃកាដាមាសក៏មាន ។ ឆ្នាំ 1957 ស៊ឹមសាតនាំយួនពីរនាក់ ❶

តាមចម្លើយនៃចម្លើយរបស់ ឈុន និង យ៉ា កាលពីខែ 10.1976 ស្ដីអំពីប្រវត្តិរូបរបស់ បង ភឹម ថា " ក្រោយសន្និសិទហ្សឺណែវ បងភឹម ទៅរៀនទៅហាណូយ ដូចពួកទៅរៀនទៅហាណូយដទៃទៀតដែរ ។ តែទៅបានមួយរយៈ បក្សយួនក៏ឲ្យបងភឹមត្រឡប់មកក្ដាប់បក្សនៅកម្ពុជាវិញ ពីព្រោះវាមិនទុកចិត្តតាមុត ដែលជេះតែនៅជាប់ជិតស្និទ្ធជាមួយ បងៗ មកពីស្រុកទ្រាំង (ពិសេសគឺ បង I) ។ កាលណោះ បងភឹម ត្រឡប់មកជាមួយ ប៊ុនសានី តែ ប៊ុនសានី គ្មានចម្លើយបែបនេះផងទេ ។ ត្រឡប់មក ខែរាំងឆ្នាំ 1956 ។

យើងកត់ ។ ពុំ [redacted] សន្និដ្ឋានចម្លើយនេះ ជាពិត [redacted] ទេ ព្រោះហួសលទ្ធភាពយល់ដឹងរបស់យើងក្ដីហើយ តែយើងកត់កំណត់ថា [redacted] គឺយួន អាចមានផែនការបង្កប់កម្លាំងក្នុង ប.ក.ក នៅក្នុងរយៈកាលក្រោយសន្និសិទហ្សឺណែវមកនេះ ។

---

❶ មកនៅភ្នំពេញ ហើយក៏ណែនាំ ស៊ឹមសាត ឲ្យមកនៅជាមួយក្រុមប្រជាជនចុះ ។ អាចារ្យ កឹង ក៏និយាយថា ពួកវាគាត់ទង រឹកាម នៅភ្នំពេញរហូត ។ សាន់ និយាយថា ពេលវៀតកុងវាដាប់គុក វៀតកុងវារៀបចំឈ្មោះឲ្យយួន មកគាត់ទងវា ។

00285373

E5/2.29

ពាក្យស្លោកបង្កប់សាយុទ្ធសាស្ត្រ : វិធីសង្គ្រោះស៊ីណេ ៤ ទិដ្ឋិ តបងស្រាប

២.– ធាតុពិតរបស់ផែនការបង្កប់ស៊ីរូងនេះ ៖–

តាមចម្លើយខ្មាំងបន្តបន្ទាប់មក ពួកដែលនិយាយផែនការនេះច្បាស់ល្អលមជាងគេ គឺមេដឹកនាំពួកខ្មែរសេរី ឬ សេអ៊ីអា ដូចជា ពួក ចក្រី, សុផាន, សីផែន, ស៊ីន សារី ហៅប៉ុស្ត៍ និងពួកកុយធួនជាដើម ។ ឈ្មោះខ្សែពាក់ព័ន្ធរបស់ ភ្នាក់ងារយួន យើងនឹងភ្ជាប់ ពុំធន់បានទេ ពុំធន់មានឯកសារបញ្ជាក់ទេ តែឯកសារដែលបញ្ជាក់អំពីដៃជើងយួនគឺ មានតែការពាក់ព័ន្ធបក្សមួយចំនួនតែប៉ុណ្ណោះ ។ យើងនឹងសូមសរុបក្នុងផ្នែកទី V ។

៣.– អំពីមាគ៌ាដាវយុទ្ធសាស្ត្ររបស់សេអ៊ីអា (យូរអង្វែង ពុំកំណត់រយៈកាលទេ)

ពួក សុផាន អនុកងពល 170 បានសារភាពអំពីខ្សែ ពាក្យ យុទ្ធសាស្ត្រថា « គ្របលាក់ខ្លួន ឲ្យនៅស្ងៀមស្ងួន ដល់ទីកាលៈទេសៈ ទើបចេញវាល » មានន័យថា ពួកវាបង្កប់ខ្លួនទុកតាមកម្លាំងបញ្ចូលក្នុង ប.ក.ក ។ ពេលណាដែលកម្ពុជា ទំរុះទំរាយ សតិអារម្មណ៍របស់ពួកបដិវត្តន៍យើង និងកើតភ្លើនវិវាទអំពីជំហរវណ្ណៈអធន ខ្លាំងឡើងៗ ពេលនោះហើយ ពួកវាដែលបង្កប់ខ្លួននេះ នឹងក្រោកឡើងវាយផ្តួលរំលំបដិវត្តន៍យើងពីក្នុងពោះវៀនតែម្តង ។

ខ្សែបង្កប់ដាវយុទ្ធសាស្ត្ររបស់ពួកវា (យកចម្លើយស៊ីនសារី ហៅ ប៉ុស្ត៍សាគោល) គឺ បង្កប់ខ្លួន ក្នុងគ្រប់ភាគីទំនាស់ទាំងអស់ បង្កទំនាស់បំបែកបំបាក់ ក្នុងភាគីនីមួយៗ ដើម្បីប្រមូលកម្លាំងមកខាងសេអ៊ីអា ហើយជាក់ស្តែងពេលអោយទំនាស់ជាមួយភាគីមួយទៀត ធ្វើយ៉ាងណាឲ្យភាគីទាំងអស់នោះខ្សោយ ហើយចុងបំផុត ពួកវាដែលបង្កប់ក្នុងគ្រប់ភាគី ប្រមូលផ្តុំកម្លាំង ផ្តួលគ្រប់ភាគីទាំងអស់ ដើម្បីដណ្តើមអំណាចជាស្ថាពរ គឺពេលគឺកំទេចកុម្មុយនីស ឲ្យអស់បន្សុទ្ធ ។ ឧ.ក. ផែនការយុទ្ធសាស្ត្រ ដែលវាគ្រោងដាក់ឲ្យ ពេលវាត្រូវចេញទៅបង្កប់ក្នុងយៀកមិញ ឆ្នាំ 1954 គឺ បង្កប់ខ្លួនក្នុងពោះវៀនយៀកមិញ ក្នុងពោះវៀនសីហនុ ក្នុងពោះវៀនយួនព្រៃនគរ ពេលឱកាសហុចឲ្យ គឺផ្ទុះព្រមគ្នា ដណ្តើមកាន់កាប់អំណាចផ្តាច់មុខរបស់ខ្មែរសេរី ។

ឧ.ក. ផែនការដែលស៊ីនសារី ទុកឲ្យ សីផែន ឆ្នាំ 1970 គឺឲ្យបង្កប់ខ្លួនក្នុង ប.ក.ក ផង ក្នុងបក្សដែលពួកយួនចាត់តាំងថ្មីផង ហើយលើកទ័ពប្រមូលកម្លាំង និងវាយបង្គ្រប់ដណ្តើម ពាក្យស្លោកដែលពួកវាលើកឡើងមកគឺ ដាក់ថ្នាំពុល បញ្ចូលទៅគ្រប់សរីរាង្គ

00285375

E5/2.29

៥. ចាត់តាំងមនុស្ស : ប្រើវិធីកុម្មុយនីស្ត ពីជំនាន់មួយទៅជំនាន់មួយ ត្រៀមជំនាន់បន្តបន្ទាប់ អស់មួយជំនាន់ កកើតមួយជំនាន់ទៀត ។

៤.– <u>វិធីសារដោះបញ្ហាបន្ទាប់ពីរដ្ឋប្រហារ:</u>

①.– ក្នុងករណីដែលបដិវត្តកម្ពុជាពុំទាន់មានរដ្ឋអំណាច ពួកវាមួយចំនួនទួលក្បាលមេឃ ម្យ៉ាងដើម្បីការពារក្បាលបក្សពួកវាផង ម្យ៉ាងពួកវាសហការជាមួយវណ្ណៈកាន់អំណាច កាប់សម្លាប់ភាគច្រើន ចាប់ដាក់ អ្នកបដិវត្តដែលត្រូវឲ្យក្លាក់ក្លាយ រួចដើរ ផង ក្នុងបំណង សំអាតសំអាង អ្នកបដិវត្ត ចេញពីទីនោះ បម្រុងទុកតែពួកវា ដែលមានតែប្រភពបដិវត្ត។

ឧទា. ឈ្មោះ ឲ្យខ្មាំងចាប់ ភាគ់ មកដាក់គុក

ឧទា. 1967 បងក្លូង ដៃណាំ ដោយសាខាត ឲ្យដើរមេភូមិ ដើម្បីការពារក្រុមបងក្លូង ផង និងកំចាត់កំចាយក្រុមផ្សេងៗទៀតដែលមិនមែនជាបក្សរបស់វាផង ។ (ចម្លើយ ដោយសាខាត លេខាស្រុក ក្លូង តំបន់ ២)។

②.– ជាមួយនោះ ជំពោះរដ្ឋប្រហារសីហនុ ពួកវាធ្វើវិជ្ជកម្មសេដ្ឋកិច្ច ដើម្បីបង្កើត វិបត្តិជីវភាព (ឧទា. នាំចូលតែរបស់គតប្រយោជន៍) ហើយជំរុញឲ្យសីហនុសុំជំនួយ ស.រ.អា និងឈានទៅក្តាប់អំណាចជំនួសសីហនុ ។ ចម្លើយរបស់ គុជ ភឿន ។

③.– ក្នុងករណីដែលបដិវត្តកម្ពុជាឈ្នះ ពួកវានឹងរួមដៃជាមួយបក្សពួកវាតែប៉ុណ្ណោះ ប្រមូល អ្នកបដិវត្ត ក៏ទេ ឲ្យសាបសូន្យ រៀបចំនាំក្រោយម្ជិលការ ។ (ចម្លើយ កុយ ធួន)

④.– ក្នុងករណីពួកវាបរាជ័យវិញ គឺពួកវាត្រឡប់មកអនុវត្តមាគ៌ាយុទ្ធសាស្ត្ររបស់ពួកវាវិញ។

---

ចំណែក យុទ្ធវិធី ស្អាត ឃើញថាត្រូវសរុប ក្នុងផ្នែកទី <u>IV</u> ។

E5/2.29

## ៦.- ការបំភ្លៃមាគ៌ារបស់ ប.ក.ក

ក្រុម ជាសេអ៊ីអា ថ្មី គឺវា ខិតខំ ធ្វើការបំភ្លៃមាគ៌ាបក្សកុម្មុយនិស្ត ដើម្បី អូសទាញ រារាំង ការអនុវត្តមាគ៌ាបក្សឱ្យវិលថយក្រោយ មហាលោតផ្លោះ មហាអស្ចារ្យ ។

ពាក្យស្លោករបស់ពួកវាគឺ បង្វែរសំពៅបដិវត្ត ហើយវាយបដិវត្តវិញ ។

សំណូមពរយុទ្ធសាស្ត្ររបស់ ពួកវាគឺ ៖

១. វាយផ្តួល បក្សកុម្មុយនិស្តកម្ពុជា ហើយបន្តរបបកាលពីសម័យលោកសៀវមកវិញ

២. តែបើមិនសម្រេច ក៏នឹងបំភ្លៃ អូសទាញ បង្ខំ ឱ្យមាគ៌ា ប.ក.ក ប្រែក្លាយ ទៅជាសេរីវិញ ដូច យួន + សូវៀត ។

នេះជាសំណូមពរ ចុងបំផុតរបស់ សេអ៊ីអា ។

ទៅវិញនេះ ពួកវា ក៏បានបង្កើតពាក្យស្លោកតូចៗ ដទៃទៀតជាច្រើនដែរ ។

ឧ. ធ្វើស្រែតាមគ្រាំង ធ្វើស្រែតាមវស្សា អង្ករបើកតាមផ្ទះការ ប្រាក់បើកតាមប្រជាជន

សរុបទៅ យុទ្ធវិធីបំភ្លៃរបស់ យួន ឬ របស់សេអ៊ីអា គឺមានតែរបៀបតែមួយ ។ ដើម្បី សូមសរុប ជារយៈកាលៗ តាមទម្រើយពួកកុយធួន , ចក្រី , ទុំ ដូចតទៅ ៖

①.- រយៈកាល មុនថ្ងៃ 18.3.70.- បក្ខពួក កុយធួន ច្រើនប្រើរូបភាពតស៊ូ តក់ក្រហល់ ក្នុងបំណងឱ្យឃើញថាវា សម្បូរ ដល់ខ្មែរ មានវិធានការបំផ្លាញ ចលនាបដិវត្ត ។ រូបភាពខាងក្រៅ មើលទៅដូចបដិវត្តខ្លាំងណាស់ តែជាក់ស្តែង ជាលទ្ធផល គឺខ្មែរ ភាគច្រើនខ្ទេចខ្ទី ។

ដៃក្បត់ ខាងភូមិភាគបូព៌ា តាមទម្រើយរបស់ពួក យួន ពួក សោមសាកាត ពួកទុំ គឺ ខិតខំកសាងមូលដ្ឋានក្បត់ តាមរូបភាពបដិវត្ត ។ កម្លាំងបដិវត្តពិតប្រាកដ គឺពួកវាសហការ ជាមួយវណ្ណៈកាន់អំណាច តាមរយៈពួកវា ដែលបាក់ការងារជាមេភូមិ មេឃុំ គឺចាត់ចែងចេញ តាមវិធីផ្សេងៗ ។

②.- រយៈកាល សង្គ្រាមរំដោះជាតិ.- បក្ខពួក កុយធួន ខាងភូមិភាគ 304 បង្កើតបរិយាកាសសន្តិសុខ ហ៊ឺហា ក្តៅក្តៅ សិល្បៈ ស្រី ពុបលាង បុណ្យ តាំងផ្ទះ ជាំបើមបេកតាមថ្នាល់ មុខរាក់បុណ្យសព្វ

គក់ទង្គ្រាំង ។ ប្រមូលកម្លាំងប្រជាជន រាប់ម៉ឺនទៅជីកប្រឡាយពីភ្នំត្បែង , ទៅកាប់ព្រៃយកដែក កុំគិតសមស្លៀ ។

ឱ្យស្រែនៅតាម ភូមិភាគបូព៌ា ឋិតក្នុងភក់ តាមពាក្យស្លោក " ដុតឲ្យខ្លោច ពាក់ឲ្យដោក "

ភ្នំ. ចក្រ ពេលប្រយុទ្ធ គឺវាញុះទឹកឲ្យស្រុក ការលើគ្រាប់ទ្រាំង តែយើងវិញ គឺកុំភ្លេចលក្ខណៈការ ធ្វើឲ្យភ្លេនទឹកមាសជើង ហើយវាលើកពាក្យថា " អស់មួយ "ម៉ឺ" លើកមួយ " ម៉ឺ " " ។

ពួក នុំ នៅតំបន់ 22 វាបាត់តាំងសហករ , ដំបូងនៃ គឺបាត់តាំងផលស្លឹក ហើយប្រមូលរបស់គេអស់ ដាក់រួម ហើយ កុំមានអប់រំប្រជាជន ។ ផល់ពេលខ្យល់ការ ហែលឲ្យរំភាយ គឺវាឈប់ធ្វើ ...

(៦)- សម័យការពារប្រទេស .- អង្គការ ហៅឲ្យ សំរុកធ្វើ ពួក ជឿន ស្វន បណ្ដក់ ព្រាយយុទ្ធជន ហើយ ហែង អ្នកផ្ញើទៅកាប់ដី ប្រចួកកូន ស្អួបត់តល់ មល់ ពួកចក្រ វាលើកពាក្យស្លោក " ស្អួងច្រាំង រលួ ... " ។ ល។ និង។ ល។

1962 ស៊ីវហេង ចេក សាយ + តាំងសា សម្លាប់តាត្រូវតាមុត ។

1956 បក្សសូវៀត ផ្សាយសេចក្ដីថ្លែងការណ៍របស់សមាជទី 20 ។ ប.ក.ក បានប្រើពីសម័យ
ក៏បក្សក្លែង ភ្ញាក់ផ្អើល ដោយខឹង ថែមទាំង ថា សៀវភៅ ដែលសួរ យ៉ាងនេះ
ទៅប្រពេញទី ។ ពួកវាយល់ថា បក្សសូវៀតជាបក្សធំ និងចាស់. សជាដគេ ។ សង្គម
កម្ពុជា ក្នុងការសិក្សាតែវណ្ណៈ ។ ប្រទេសកម្ពុជា ត្រូវការសន្តិភាព មិនត្រូវធ្វើបដិវត្តន៍ទេ ។
សីហនុ ជាអ្នកដឹកនាំដែលត្រូវមន្ទីរ ។ ពួកវា [illegible] លើសពីនេះក្នុងបក្សវិញ ។

1964-65 ហ៊ូនឹម ហ៊ូយន់ លោកដោយ វណ្ណៈក្ដុសវណ្ណៈនៅយុទ្ធសាស្ត្រ ដែយនុន
ក្នុងប្រជាប្រឆាំងបក្សយួន

## IV.– អំពើ ផែនការសេអ៊ីអា និង យួន ក្នុងរយៈកាលនីមួយៗនៃបដិវត្តយើង
### (សូមលើកយកតែឡើយ កុម្មុយនិស្តយួន ជាគោលសរុប)

ក្នុងគ្រប់រយៈកាលតស៊ូ ក្នុងប្រវត្តិនីមួយៗ សុទ្ធតែមានជនក្បត់ជាប់បញ្ហាស្មុគស្មាញ យ៉ាងច្រើន គណៈមជ្ឈិម ម.ឈ.ប.ក.ក ជាអ្នកដឹកនាំ ទាំងលើក ទី I និងទី II ។

ក.– រយៈកាលមុន 18.3.70.–     ①.– អំពើផែនការសេអ៊ីអា

– មុនកុម្មុយនិស្ត ទៅកំពង់ចាម ហង្សរដ្ឋនហាក់ ឲ្យកុម្មុយនិស្តរាយការណ៍ អំពីឈ្មោះ បងៗ និង កន្លែងប្រជុំ ដូចនេះ ការបង្ក្រាបពេលនោះ មានភារកិច្ចប៉ុណ្ណោះ ។

– ឆ្នាំ 1960 ក្រោយការចូលបក្សបានបន្តិច ហង្សរដ្ឋនហាក់ និង ហ្មកឌី ឲ្យកុម្មុយនិស្តទៅកសាងមូលដ្ឋាន ប្រជាជន ក្រោមស្លាកបដិវត្ត នៅកំពង់ចាម ។ ភារកិច្ច គឺកសាងឲ្យខ្លាំង បង្កប់ខ្លួនឲ្យជ្រៅក្នុង អង្គការដឹកនាំ ហើយរកមធ្យោបាយ បំផ្លិចបំផ្លាញ កម្លាំងបដិវត្ត ។

– ឆ្នាំ 1966 សន្និបាត ម.ឈ បក្ស សំរេច ឲ្យត្រៀមតបតស់ យុទ្ធសាស្ត្រ គាំទ្រការធ្វើរដ្ឋប្រហារ ។ ពួកកុម្មុយនិស្ត ក៏ធ្វើសកម្មភាពបំផ្លាញកម្លាំងបដិវត្តខ្លាំង ដើម្បីជំនួយដល់រដ្ឋប្រហារ ។

– មុនរដ្ឋប្រហារមួយខែ ហង្សរដ្ឋនហាក់ បានហៅ កុម្មុយនិស្ត-ភឿន-ស្រេង ឲ្យមកជួបសុំរង្វាន់ ជា ភ្នាក់ងារសេអ៊ីអា គោលនៅភ្នំពេញ ដែលនាំឲ្យបំផុសមហាជន គាំទ្ររដ្ឋប្រហារ, ព្រោះតែបោសសំអាត កម្លាំងបដិវត្ត តាមរូបភាពអំពាវនាវ និងកំទេច, ចេញ ទាំង យៀកកុងឲ្យផុតពីកម្ពុជា ។

ត្រង់ "ខ" នេះ ខ្ញុំ ក៏សារភាព ជា បានចូលការ ថែរក្សា អំពើ បង ស៊ិន ដែរ ។

②.– អំពីផែនការ យួន

សូមលើកយកតែឡើយ ពួកមកពីវៀតណាមហាណូយជាគោលសរុប ។ ចឡើយពួកគេ ក៏មាននិយាយដែរ តែពុំមានសកម្មភាពច្រើនប្រស្នុំ ព្រោះការធ្វើសកម្មភាពពេលនោះ ការសួរពេលនោះ ពុំបានគិតយុទ្ធសាស្ត្រ និងតែជំពោះមុខ ។

បក្សយួន មានផែនការ វាយរំលំបដិវត្តយើង ដូចសេអ៊ីអាដែរ ដោយកាលថា គាំទ្រវិធានៈ យួនខាងត្បូងនិង ហ៊ីមហ៊ា មកជួយ ។ តាមរយៈរូបភាពនេះ វាដំរិលរបទឹកដីកម្ពុជា ដោយឲ្យ ពួកមកពីវៀតណាមហាណូយ ភ្ជាប់ ខ្សែអំណាចឲ្យបាន ដោយសហការជាមួយទីភ្នាក់ងារយួន ដូចសម័យវាយផ្តួលរំលំ

ជំពែក ពួកអាក្លូ ក៏ធ្វើសកម្មភាព បំផ្លាញកម្លាំងប្រទ្វ កសាងមូលដ្ឋានរបស់វា ហើយ ពោលថាឲ្យរង់ចាំពួកមកពីហាណូយ ឲ្យរង់ចាំទ័ពយួនមកជួយ ឲ្យអស់សង្ឃឹមលើអង្គការដឹកនាំខ្មែរ

E5/2.29

④- ដី ដែនកោះ ក្រុកមិនគាំ ...

1949 ដាច់កាលដាក់ ទក់មក កោះត្រល់ ។ វាលើកយុទ្ធសាស្ត្រ វាយយកប្រទេសជិតវិញ
ពេលមួយស្រុកក្រោយមក ។ អាមេរិក ស៊ុំ ហ៊ីស៊ីធ ដែលទៅដុំវិញ កោះត្រល់ជា
ដីខ្លួន ។ ក្លាយទេះ ប្រទេសទី 7 របស់អាមេរិក បំផុ បំពុះផ្ទុះសង្គ្រាមជិត ។
ក្រោយ បក្សបៀងទៅក្រៅ ដើម្បីឲ្យជិតរំដោះ វិតតិក្នុង វិសេស ការដោះស្រាយជំរកាត
ប្រជាជន ។ វាឈ្លើះ ដើម្បីឲ្យប្រជាជនជិត ដំរីជិត ជើ ប.ក.ជិត ហើយប្រើវិជិត ។ វាវាយឥស្រ
ដើម្បីឲ្យប្រជាជនជិត និងឲ្យរបស់កោះត្រល់ ទៅរស់ក្នុងប្រទេសជិត វាយតក្កនយោបាយ ។
កែមិនបានសំរេច ។

1972 អាជ៊ីគ្រុម និង ជិន ទេញប្រកាសរួម ភាពនៃ យើលាង ផ្ទើការ រាក់ទង ខ្លួន ។ ពេលនេះកោះត្រល់
ឲ្យប្រកាស គាក់ង ស្ទៀតវិញ ក្នុងការដើ គេមេរិកវិសដកដយកកោះត្រល់ ។ ស្ទៀតក៏វាយស្រេច ក្នុង
យុទ្ធការស្រុកប្រយុទ្ធជិត ដូចគ្នា ។ កោះត្រល់ វាយសំលៀមមោយកាយ ថា លើវិនិយ និង អតៃប្រស់
ដាឃ្លួនគ្នាបាន ទើយវាកេះដាក្លង វាទីបាន ។

ក្រោយ 17.4.75 កម្ពុជាវិនោះ កោះត្រល់ យកជិតក្នុងដាក់ពិណាះកម្ពុជាវិញ ។ វាវេចាក់ឆ្មើលកម្ពុជាឡើង ដូចនេះ
លើកម្ពុជា ដូច បូវអាស៊ីអាគ្នេយ៍ និងប្រទេសទាំងឡាយ ។ ដូចនេះ វាក៏លើកយុទ្ធសាស្ត្រ ឈានការដាឃ្លួន
យួន វាយកម្ពុជា ។
ដែនកោះ ដែល គេឃើញ ថ្ងៃ 3.1978 របស់ក្រុមក្រុកមិនគាំ គឺ ដែនការវាយបញ្ចូល 17.4.75 ដែល
មានលក្ខណៈ ដូចស្ដុកគោ និង ដែនការ លេសុីកា ដែនការ យួន ។

របស់ ប.ក.ក ។

ក្បាលម៉ាស៊ីន អនុវត្តផែនការ យួន ដំណាក់នេះ គឺ សឹង ង៉ុកមិញ និង កែវមាស ។ កែវមាស វាចេញទៅយួន ប្រហែលឆ្នាំ 1968 ។

③.- អំពីផែនការ សូវៀត .-

សូមលើកយកឧទាហរណ៍ ពួកនិស្សិតមកពីរៀននៅសហភាពសូវៀត ជាភ្នាក់ងារ កាសេប ជាគោលសរុប ។

- សូវៀត វាមានផែនការភ្ជាប់និស្សិតដែលទៅរៀនស្រុកវា សម័យដំណាក់សីហនុ ។ ភ្ជាប់ តាមរយៈ ក្លឹប ម៉ាក្ស លេនីន ។
- ឆ្នាំ 1965 កាសេប ចាត់តាំងបក្សកុម្មុយនីស្តខ្មែរ មួយ ដែលមាន ហាក់ឡៀងឡាយ ជាលេខាបក្សនេះ ។ ពួកវាបានបញ្ជូនកម្លាំងមួយជំនួន[1] មកកសាងជាមួយសីហនុ តែ ត្រូវរដ្ឋអំណាចសីហនុ ក្បែរជាប់ ធ្វើអ្វីមិនកើត ។ ដូច្នេះ សកម្មភាពពួកវា បានតែ ប្រមូលកម្លាំងនិស្សិតនៅប្រទេសបារាំង ដូចជា គួនគាំសឿនទៅបារាំង , អ៊ំដូបី ជាដើម ។ ពួកវា និយាយ ជួនមុំ ដែរ ។

9.- រយៈកាល 5 ឆ្នាំនៃសង្គ្រាមរំដោះជាតិ .-

①.- អំពីផែនការ សេអ៊ីអា

- ក្រោយរដ្ឋប្រហារ ចលនាមហាជនជាបាតុកម្មប្រឆាំងរដ្ឋប្រហារ 18.3.70 កើតកក្រើក ។ ពួកកុយ ធួន ពួកនុំ ទប់ចលនានេះមិនបាន ក្លាយកែកមុខមាត់ កំបាំងខ្លួនតាមចលនា ។ បន្ទាប់មក កុយ ធួន និង ត្រាប មកឆ្លៀត ហង្ស ធុនហាក់ ពួកវាក៏ឡូលផែនការដូចតទៅ :
  - ពង្រីកបរិវេណ បរលន់ក្រុល , សហការ ជាមួយ ពៅហ្មួយ ទេត្ត កំពង់ចាម, កំពង់ធំ, ស្វាយរៀង
  - ចាត់តាំងកម្លាំងក្បត់ ក្នុង ទ័ពយួន , ទ័ពបដិវត្តកម្ពុជា, និងចាត់តាំង រដ្ឋអំណាចថ្មី ដោយសមាសភាពក្បត់
  - រៀបចំឲ្យលេណដ្ឋានក្នុងតំបន់រំដោះ , ឈ្លបធ្លាក់ ... ធ្លាក់គ្រាប់បែកលើទីតាំងសំខាន់ៗ
  - បំផុស ទំនាស់រវាងប្រជាជន និងទ័ពយួន , រវាងទ័ពបដិវត្ត និងទ័ពយួន ហើយភ្ជាប់ ទ័ពបដិវត្តឲ្យបាន ។
  - ទំនាក់ទំនងឲ្យតាក់តែង ក្រវ៉ាស់ បង្កើតគណៈកាត់ទៅយួន ២៩ ភូមិភាគ 304 ដែលជាភ្នាក់ងារ

---

[1] ដូចជា អៀង សីហា

ភ្នាក់ងារ សេអ៊ីអា ជើងចាស់ម្នាក់ ក្នុង ម.ឈ បក្សយួន ។

• ពីពេលនៅ ស.រ.អា សេអ៊ីអាបានចាត់តាំង ហ្គូតសម្បត្តិ ឲ្យចូលមកបង្កប់ខ្លួនក្នុង ស.រ.ជ.ក នៅប៉េកាំង ។

៣ក. សភាព កាំតាំងពួកកុយធួន , សមាសភាពបែកមុខ វាដកចេញ តែអាក្បត់មួយទៀតត្រូវបន្តុប ឡើងវិញ ។ ដូចនេះពួកក្បត់ត្រូវដកបន្តុំឈ្មោះ តែកត្រូវបញ្ចូលវិញបន្តបន្ទាប់ដែរ ។ល។

៣គ. ឆ្នាំ ១៩៧១ ពេលប្រជុំ ម.ឈ ទុំ វ៉ាក់ស្នាំង បងភឹម អំពី វណ្ណបក្សយួន ព្រោះតែមានការណែនាំ របស់បងពាម អំពីការប្រឆាំងយួន ។ល។

- ដើមឆ្នាំ 1974 កុយធួន មកធ្វើការជាមួយហង្សធុនហាក់ ។ ហង្សធុនហាក់ក៏សារភាព អំពីការទាក់ទង ហៃមាស - យ៉ាំ - ធុង ដែលហង្សធុនហាក់ ឧទ្ទេសនាម ជាជាសេអ៊ីអា ពីដូនឆ្នាំ 1964 ស្រុក ឧទ្ទេសនាម អំពីផែនការ ចាត់តាំង បក្សថ្មីមួយ ជំនួស ប.ក.ក បក្សយួន ។ តាមរយៈ បក្សថ្មីនេះ សេអ៊ីអា បញ្ចូល របបសេរី ទៅ ដែបយួន ហើយ ស.រ.អា នឹងជួយផ្គត់ផ្គង់ ។

បញ្ចេះ: ហង្សធុនហាក់ ឲ្យវា ទាក់ទងជាមួយ ហៃមាស , យ៉ាំ ឬធាវីថ៍ ។

ផែនការមួយទៀត គឺ ពង្រីក បរិវេណ ឧត្តរ ។

- ខែ 6.1974 សភាពការណ៍សមរភូមិមានការប្រែប្រួល ។ ហង្សធុនហាក់ ភ័យខ្លាំង ហើយឲ្យវា ខិតខំរាវរក ឲ្យវាវាយការណ៍អំពីទីតាំងទ័ព ជំរុំរកមិនបាន និងកន្លែងបន្ទា វាក៏វាយការណ៍ តាមកាលកាលៈ ដើម្បី ពន្យារការស្លាប់របស់បក្សពួក ។

សកម្មភាព កុយធួន វាទាំងខ្លះ វាយខ្លះ ពេលដែលសមរភូមិដាច់ វាយខ្លាំង ហើយ វាខ្លាច បែកមុខ ក៏ជំរុញ ទ័ព ឲ្យ សំរុក ដូចគេដូចឯង ចាប់ពីដើម ខែ 4.1975 ទៅ ។

- <u>អំពីផែនការ</u>ត្រៀម<u>បាញ់</u>.-

សូមសរុបតាមចម្លើយ ពួក សេអ៊ីអា ជាភ្នាក់ងារបរទេសកសិកម្ម ជាអ្នកធ្វើការ ភាសា នៅភ្នំពេញ ។ ពួកវាបានរៀបចំ ផែនការ ពិសេស ពួកកម្លាំងចំបំ ដើម្បីវាយក្រញ៉ាំបំណើង ពេលកងទ័ព យើង ចូលដល់ភ្នំពេញ ។ តែផែនការនេះ ទុំមិនបាន ដោយកងទ័ពយើង វាយដល់ទីណា គឺជំលៀសប្រជាជនចេញពីទីនោះភ្លាម ធ្វើឲ្យកម្លាំងត្រៀមទុករបស់វា ត្រូវបែកខ្ញែកគ្នា ទៅតាម ទៅជាមួយប្រជាជនអស់ ។

②.- អំពីផែនការបក្សយួន ⊕

1- ពួករៀនទៅហាណូយ មុនថ្ងៃដំណើរត្រឡប់មកស្រុកវិញ បក្សយួនបានផ្ដាំផ្ញើថា
- ត្រូវក្ដាប់កងទ័ព, ក្ដាប់មូលដ្ឋាន ជាដើមឲ្យបានក្នុងដៃ ។ កងទ័ពយួនពីកងពល នៅពីក្រោយខ្នង ។ ត្រៀមដំណើរការ ផ្ដួលរំលំរាយបាញ់ ។
- កុំភ្លេច បក្សនៅក្រៅប្រទេស (គឺ ស.ម.ម និង វៀតណាម)
- ត្រូវទាក់ទងជាមួយ អតីតតស៊ូ ដូចជា បង ភឹម, បងញឹម, បងស៊ី, យ៉ា និងជុំ ដែលជួប យ៉ា សិន ។ ចម្លើយរបស់ ស៊ីនសាវៃ ហៅ ស៊ុប ដែលឆ្លើយខ្លីសរុប ថ្ងៃ 13.5.76 ដែលរាយការណ៍ជាតណាជាតណ ។

2. ពេលវាយរំដោះ កុយធួន ទៅផ្ញើជាមួយអង្គការ ។ ចុះមកវិញ យ៉ា ឲ្យសម្រិតសម្រាំង ជាង មកជាមួយ សៅហឿង និង ប៉ាទីង ។ យួនផ្ដល់ឯកសារបក្សដល់យួន បន្តបន្ទាប់ ។
1973 យ៉ា ប្រាប់ កុយធួន អំពីយួន ជួយបាត់ការបក្ស ជាមួយ ដែលមាន វៀតណាម ជាប្រធាន ។
ថ្ងៃ 5.4.74 យ៉ា ប្រាប់យួន អំពីពួកហាណូយ មាន ម៉ីជូ, អាច្បវ័ង, ធន, យស់, តាន, ភឹម, រ័ បានប្រជុំជាមួយ យ៉ា អំពីការប្រឆាំង ប.ក.ក ។ ស៊ីនសាវៃ ហៅ ស៊ុប ក៏សារភាពថា 6.74 និង 8.74 ហ៊ីងណារិន មកជួប ម៉ីជូ នៅកំពង់ធំ ដើម្បីពិភាក្សា អំពីការបង្កបង្កើតបក្សមួយទៀត ។

3- កណ្ដាលឆ្នាំ 1974 បក្សបានប្រជុំ ម.ឈ លើកផែនការវាយផ្ដាច់ព្រ័ត នៅដើមឆ្នាំ 1975 ។ ចប់ប្រជុំ បង ភឹម បានមកជួប ខ្ញុំ វ៉ាណា និងខ្ញុំ ដូចតទៅ÷
(ចម្លើយ ផាត ផៃ ហៅ ទុំ ក្នុងខែអគ្គថ្ងៃ 3. វិច្ឆិកា. 1977 ទំព័រ.26 .27)
- ប.ក.ក នឹងគ្រប់គ្រងនូវលទ្ធភាពរំដោះគឺចំណាស់ ហើយពុំមានលទ្ធភាពរំដោះទាំងស្រុង ក្រោយឆ្នាំ 1975 នេះទេ ។ ក្នុងករណីនេះ ខ្សែក្លាត់ត្រូវការពារកបរំដោះឲ្យបាន ដើម្បីរក្សាកម្លាំងខ្លួនផង ដើម្បីត្រៀមពេលខ្សែក្លាត់ត្រូវការ រំដោះទាំងស្រុងផង ។ និងវាយជីវិតឲ្យ ដើម្បីបញ្ចៀសភាពការពារពេលឲ្យយល់ ឆ្នាំ 1976 ដែលផែនការ បក្សយួន ចូលមកដូចជាមួយខ្សែក្លាត់ ។ ទ័ពយួនសំរុកចូលដូចឆ្នាំ 1970 ។
បើកងទ័ព បដិវត្តន៍ អាចរំដោះពេលណាមួយនេះ នោះ ខ្សែក្លាត់ត្រូវសម្របខ្លួន ដើម្បីបង្កប់ខ្លួនតទៅទៀត ។
- ជំហានៈ ផែនការនេះ គឺឲ្យខ្ញុំមកជួបយួន ដើម្បីរាយការណ៍ឲ្យយួនដឹង ។

---

⊕ សូមបន្ថែម ចម្លើយផ្សេងទៀត នៅក្នុងផ្នែកទី V. ខាងមុខ ។

00285385



៤. ផែនការ ដណ្ដើមអំណាច អំពី ប.ក.ក ក្រោយឈ្នះក្លូម.-

សូមយកឧទាហរណ៍ ពួកវៀត ស៊ុក តំបន់ 25 ជាគោលសរុប ។ តាមដែលយើងខ្ញុំដឹងពី ពេលដែលយើងខ្ញុំទទួលភារៈសួរនៅឡើយ ពួក រុងត្ត និង ពួក ចក្រី ក៏មាននិយាយដែរ ។

ពួកវាក្បត់ ក្នុងការ ពេលដែល កងទ័ពរំដោះ បំផុសបាតុកម្ម ពីតំបន់ 25 ចូលមកភ្នំពេញ គឺត្រូវដោយ ទ័ពក្បត់ដែលបង្កប់នៅមូលដ្ឋានតំបន់ 25 និង កងពល 703 ត្រៀមចាប់បង្ក្រាប នៅភ្នំពេញ ហើយប្រកាសអំណាច ពួកវា ។ ពួកវាធ្វើដោយ សហការ ជាមួយ តំបន់ 24 [redacted] តំបន់ 15 ។ល។ ផង ។ ការណ៍នេះ ពួក 25 វានិយាយ ជាក់ច្បាស់ណាស់ ពីមានមូលដ្ឋានវិភាគធ្វើបញ្ជូន ។

③.- អំពី ផែនការ ស៊ូវៀត.-

ក្រោយរដ្ឋប្រហារ 18.3.70 ក្លូម ស៊ូវៀត វាបញ្ជូនពួក ហាក់ស៊ីវៀនខ្មែរ ឲ្យ ចូលមកក្នុង រណសិរ្សរួបរួមជាតិកម្ពុជា ។ ពួកវា ពិការក់ឲ្យធ្វើការ ចាក់ចង ជាមួយ ពួកកាលីន លោកយ៉ា និង ពួកបក់ពីវៀតណាម ។ ក្នុងការ ការពារការណ៍ នៅក្រៅប្រទេស ពីកាលណោះ ពីឲ្យចាក់ចង នៅ ខួត យួន ឌុយចា ។ល។

៣.- រយៈកាល ការពារប្រទេស

យើងខ្ញុំបានសរុប ក្នុងផែនការរួមចុងក្រោយ នៅ ចំណុច ទី 1 និងទី 2 ហើយ ។ ពេលនេះ យើងខ្ញុំសូមសរុប តែ ផែនការ ស៊ូក ដែល យើងខ្ញុំក្ដាប់បានខ្លះៗ តែប៉ុណ្ណោះ ។

①.- ផ្នែកខាង ក្រៅប្រទេស.-

- ខាង សេអ៊ីអា.- ពួកវាបញ្ជូន ភ្នាក់ងារ ក្រុម ដែលនៅក្រោម ស.រ.អា ឲ្យចូលមកកម្ពុជា តាម រូបភាព អ្នកជនបរទេសអ្នកស្នេហាជាតិ ដូចជា ស៊ួង ជាញ់ , [illegible] , ស៊ុំស៊ីឡូណា , គឹមក្បៀកក្បៀង ជាដើម ។ ពួកនេះ មានភារកិច្ច មកចាក់ចង ខ្មែរសេរីអ៊ីអា ខាងក្នុងមាន កុយធួន - ននសួន - ភោកឆាយ - ចេងសាយុំមបិន - លីផែន ជាដើម ។ ម្យ៉ាងទៀត ដើម្បីបង្កប់ កម្លាំងទៀត ដើម្បីយកការណ៍ និងនាំគ្នាមកពីក្រៅខាងក្នុង ឲ្យចាក់ចេញ នៅក្រៅប្រទេសវិញ ។

ចំណែកពី ខាងវៃ ក៏មានបញ្ជូលមក តាមរូបភាពផ្សេងៗ ជាបន្តបន្ទាប់ដែរ ។

- ខាងយួន ក៏ដូច្នេះ ។ ឧ. វាបញ្ជូន លីប៊ុនឈាង ដែលរត់ចេញពីកម្ពុជា ខែមេសា 1975 ឲ្យចូលមកកម្ពុជាវិញ ថ្ងៃ 1.1.76 តាមរូបភាពបញ្ជូនជនភៀសខ្លួន ឲ្យមកកម្ពុជាវិញ ។ លីប៊ុនឈាង ជាសេអ៊ីអា ជាតបាន ។ ស្ទើរតែមិនឲ្យ វាច្រើឲ្យពាំនាំផែនការវាយលុកលួចពាររបស់បក្សយួន និងការណែនាំឲ្យខ្សែរត់ក្នុង ត្រៀមឃោសនា គាំទ្រទ័ពយួន ពេលវាយលុកនោះ ។ ខ្សែរត់ក្នុងគឺ គួចកៀនៈភិន ប្រធានក្រសួងពាណិជ្ជការ ។

ក្នុងខែមករាវាយលុកនេះ គឺយួន ចង់ប្រើពួកដៃជើងសេអ៊ីអា នៅយួន និងនៅថៃ ឲ្យលុកឡុកមុន ដូចពេលចូលលុកបានហើយ ទ័ពយួន និងសុំចូលក្តាប់កម្ពុជា តាមរូបភាព មកជួយកម្ពុជា ។

②.- ផ្នែកខាងក្នុងប្រទេស.-

ខ្សែរត់ក្នុងចាស់ ពីត្រៀមលក្ខណៈសម្បត្តិ ធ្វើរដ្ឋប្រហារ ប.ក.ក ។

1- ក្រោយថ្ងៃរំដោះ ពួកវាឆ្លៀតឱកាស ពាលបក្ស សុំកម្លាំង បង្កើតក្រសួងនានា ពួកកម្មករ ពួកចក្រី បញ្ចូល និងបញ្ជូន សមាសភាពក្បត់ជាដៃជើងវាមក ។ ធ្វើឲ្យបរិយាកាសខ្មាំងបង្កប់ មានគិតៗមានច្រើន ក្នុងគ្រប់កន្លែងនៃទីក្រុងភ្នំពេញ ជុំវិញ ក្បាលម៉ាស៊ីននៃបក្សដឹកនាំរបស់យើង ។

ត្រៀមនេះ: ពួកវា ដើរប្រមូលក្លក់ស៊ារចាស់របស់វា ដែលរៀបដំល្បែងចេញពីភ្នំពេញ មកលាក់ ដូចជា ស៊ៀវទាំស៊ី ហៅក្លៀរ ការដើរប្រមូលជាដើម ។

2- នៅតាមភូមិភាគនានា តំបន់នានា ដែលពួកវាគ្រប់គ្រង ក៏ធ្វើរបៀបដូច្នេះ ។ នៅភាគពាយ័ព្យ ដែលលេចធ្លោជាងគេ គឺ ពួក វ៉ានប៉ែន ហៅស៊ូ និង ម៉ែនសុន ហៅហ៊ីង វាប្រមូល ពួកដំល្បែងថ្មី ដែលសុទ្ធតែជាសេអ៊ីអា ( ពត់តាមគណៈកម្មការស្រាវជ្រាវខ្សែសេអ៊ីអា ) មកពត់តាម ក្តាប់មេដ្ឋការសសៀងៗ ក្តាប់កងចល័ត ។ល។

ពួកវាធ្វើដូច្នេះ តាមភាសារបស់ ឈ្មោះថា **បង្កើតរដ្ឋអំណាចក្បត់ នៅក្នុងរដ្ឋអំណាចបដិវត្ត ឬជា បង្កើតរដ្ឋក្នុងរដ្ឋ ។**

3. កន្លែងនីមួយៗ មានបង្កើត កងពិសេស សំរាប់ធ្វើឃាត និង វិទ្ធង្សនកម្ម ។ សកម្មភាពចោរព្រៃ សកម្មភាពពាលាផ្សេងៗ សកម្មភាពសន្តិសុខ ធ្វើឲ្យ ពាក្យចចាមអារ៉ាម បំភិតបំភ័យ កុំឲ្យមានសន្តិសុខក្នុងសតិអារម្មណ៍មហាជន ។ល។

ឃ- អ្នកដឹកនាំស្នាក់ប្រហារ

1975 : អ្នកជាប់ស្នាក់ប្រហារ គឺ ពួកការពារសុខសាធារណៈ + ពួកនគរបាល ស្រុក ដ៏25

1976 : អ្នកដឹកនាំស្នាក់ប្រហារ គឺ ណុន សិរីន ។ ដឹកនាំប្រយោលគឺ យ៉ា ។

អ្នកអនុវត្តផ្ទាល់ គឺ ធឿ សុផាន កងពល 170

ពីខែ 6.76 ចាប់ខ្លួន ធឿ

ថ្ងៃ 28.8.76 ចាប់ខ្លួន ណុន

ថ្ងៃ 20.9.76 ចាប់ខ្លួន យ៉ា

4.1977 : អ្នកដឹកនាំស្នាក់ប្រហារ គឺ ឃួន ឌឿន ហៅ ឌូចអៀវ កាយណាយៗ

30.9.77 : ———— ដដែល ។ ប្រយោលគឺ បងស៊ីន បងវ៉ី ។

4.1978 : ———— បងវ៉ី , បងស៊ីន ។ បក្សពួកមាន ហង់ - ចន - ម៉ា - ភិ ហុង, ជិន , សាយ នូរពួកក្ស

4.- ក្នុងការអនុវត្តផែនការ ពីពួកវាធ្វើឲ្យក្រើកក្រខះ មហាភ័យ គ្រប់ពេលវេលា គ្រប់សន្និភាព ដូចជា ភាគ ពួកវាជា ធ្វើជ្រៀតជ្រែកមិនបានពីធ្វើដែរ ចូលរួមតាមសន្តិភាព ។

③.- ខាងក្នុងប្រទេស និងខាងក្រៅប្រទេស ពីពួកវាទាក់ទងគ្នាជាប់ ។

ឧទា. ពួក ស៊ុនស៊ឹម អានហៅមុំ អនុសេនា តំបន់ 105 , ឈូក សោភ័ណតំបន់ 24 ទាក់ទងទៅយួន តាមរូបភាព គណៈទាក់ទងកម្ពុជា-យួន ។

ទៅថៃ ក៏ដូច្នេះ ។

ក្រៅពីរូបភាពស្របច្បាប់ ពី ពួកវាបាត់តាមកម្លាំងឲ្យទៅទាក់ទងជាសម្ងាត់ ថែមទៀត ។

## ឃ.- សេចក្តីសង្កេតលើផែនការនេះ:

①.- បញ្ហា សូវៀត , យួន , ស.រ.អ សហការគ្នាក៏តែណាយើងក្តីពុំគង់ក្តាប់ជាប់នូវការណ៍ច្បាស់លាស់ សំរាប់ធ្វើជាមូលដ្ឋានវិភាគទេ តែបើយើងលើ[redacted] ហេតុផលខ្លះនៃចម្លើយខ្មាំង ដូចជា ÷

- ចម្លើយ ស៊ឹម ណៃ ហៅ ប្រេង ថា បង្កប់ខ្លួនក្នុង ប.ក.ក , បង្កប់ពីក្នុងបក្សថ្មីដែលយួនបាត់តាំង ហើយពួកវាត្រៀមទ្វីការ វាយផ្តួល តាម សឹងខាង ។
- ចម្លើយ កុយ ធួន ថា ក្តីពុំទុកចិត្ត យួនទេ តែដោយផលប្រយោជន៍ក្បត់វាត្រូវតែស៊ើយ កំសហការ (បង្កើតបក្សថ្មី) ទៅ ។
- ចម្លើយ ឡេង ស៊ឹមហាក់ ហៅ ស៊ី ដូចគ្នានេះថា អាមេរិក វាស៊ើយួនសិន ដោយ ចេញជាមួយសូវៀតឲ្យត្រូវគ្នា ព្រោះអាមេរិក វាអត់កម្លាំង វាយកម្ពុជាទេ ។
- ចម្លើយ ស៊ី ប៊ុនណាង ថា យួន វាមានផែនការលើកម្លាំងចិនកោះស៊ូកុ ដែលនៅរស់ក្នុង ប្រទេសថៃនិងយួនឲ្យវាយ រួចវាមកស្រុបយក តែម្តងតាមថ្នឹមការ គេបាចទីកម្សៀវ យួនចុះបាប់គ្រី ឬត្រីយត្រេចត្រៀតតាង ។

ដឹងអស់នេះ បញ្ជាក់ថា សូវៀត យួន អាមេរិក វាសហការគ្នាតាមរូបភាពផ្សេងៗ ពីរប្រើ សើគ្នាទៅវិញទៅមកទេ តាមទស្សនៈការយល់ឃើញផ្សេងៗ ពុំមែនអង្គុយចរចា រួមគ្នា ដ៏ខ្លី នោះទេ ។ ទុកជាខាងណាឈ្នះក៏ដោយ ក៏ម្នាក់ៗមានផលប្រយោជន៍ តាមដៃរៀងៗខ្លួនដែរ ។

②.- សភាពការណ៍ថ្មីៗ មកដល់ដំណាក់ការ ទី៣ យួន វាយលុកឈ្លានពានពីក្រៅ មកតាំងកំពែងហើយ ដូចនេះ ផែនការដុងក្រោយនេះ ក៏ចាស់ទៅហើយ ឃើញក្តីពុំគង់មានពន្លឺ ក្នុងផែនការថ្មីទៀត

/

00285389



- បញ្ហា សហព័ន្ធឥណ្ឌូចិន , បក្សកុម្មុយនិស្តឥណ្ឌូចិន

## V.- បញ្ហា បក្សមួយទៀតរបស់ យួន និង សេអ៊ីអា

ក.- អំពីឈ្មោះបក្សក្បត់.- តាមចម្លើយសារភាពរបស់វាវា មានឈ្មោះច្រើន ៗ គឺ បក្សកុម្មុយនិស្តថ្មី, បក្សកុម្មុយនិស្តកម្ពុជាបដិវត្ត , បក្សកម្មករ , បក្សប្រជាជន, បក្សសង្គមនិយម , បក្សពលករ ។ល។

តែភាគច្រើន គឺពួកវានិយាយជាឈ្មោះ បក្សពលករកម្ពុជា ។

ខ.- អំពីរយៈកាលនៃការកកើតបក្សក្បត់.-

①.- ក្នុងខែ 11.1961 កែវមាស បានប្រើ អ៊ុម ណេង មកហៅ នន-សួន ទៅប្រជុំ នៅផ្ទះ អាចារ្យ សៀង ហៅ យ៉ា ។ ចូលរួមប្រជុំ មាន

1. កែវមាស
2. នន សួន (សាមីខ្លួនសារភាព ជានេះ លោកសិក្ខមន្ត្រី)
3. យ៉ា
4. អ៊ុម ណេង ហៅ បងវី នៅតាក្តួសព្វថ្ងៃ

ពេលប្រជុំ កែវមាស ប្រកាសសម្ងាត់ថា ក្រុមប្រជាជន និងប្រែថាជា បក្សប្រជាជន ដែលមាន កែវមាស ជាលេខា , នន សួន ជាអនុ , យ៉ា ជាសមាជិកអចិន្ត្រៃយ៍ , បងស៊ី និង បងវី ជាសមាជិក ។ តែពេលប្រជុំនេះ បងស៊ី ពុំបានចូលរួមដែរទេ ។ កែវមាស បានប្រាប់អង្គប្រជុំថា បងស៊ី បានប្រាប់ផ្ទាល់មាត់រួចហើយ ។

កែវមាស បានកំណត់យក ឆ្នាំ 1951 ជាឆ្នាំកំណើត ។

②.- ចំពោះ បក្សរបស់ សឺង ង៉ុកមិញ ដែលយួនបីបាច់រក្សា និង បក្សរបស់ ហាក់ សៀងឡាយនី ដែលសូវៀតបីបាច់រក្សា សុទ្ធតែនៅក្រៅប្រទេស ពុំជាប់មហាជនក្នុងប្រទេសទេ ។

ពួកនេះ រត់ចូលស្រុក ដោយមកពឹងផ្អែកលើក្បត់ក្នុងប្រទេស ដែលមាន យ៉ា ជាមនុស្ស ដែលពួកវាត្រូវមកទាក់ទង ។

③.- តែបើតាមសារភាពការ ឆ្នាំ 1974 ក្នុងចម្លើយ កុយធួន និង ស៊ីនសារី ហៅ ស្រេង និង ទុំ (ទំព័រ 17-18 នៃអត្ថបទសរុបរបស់សមមិត្តនេះ) សភាពការបង្កើតបក្សថ្មី ដើមកំ

ចាប់ផ្តើមទៅទៀត ។.

④.- ចំណែក ពួកបញ្ញវន្តវិញ ដូចជា តូច ភឿន, ហ៊ូ យន់, ហ៊ូ នឹម, ចោក ឆាយ, វណ្ណ ទិព សុវណ្ណ ក៏មានរៀបចំបក្សសេរីកម្មមួយដែរ កាលពីឆ្នាំ 1964-1965 ។

ក្រោយសភាពការណ៍ ក្រោយថ្ងៃ 18.3.70 ដែលមហាជនបាក់មករក ប.ក.ក, ដែល ប.ក.ក មានកម្លាំងខ្លាំងក្លា ពួកវាទាំងអស់នេះ ក៏រត់ចូលមករស់នៅធ្វើសកម្មភាព ក្នុងក្របខណ្ឌ ប.ក.ក វិញ ។ ភាគសុទ្ធជា ធ្វើសកម្មភាពក្នុង ក្រោម ប.ក.ក ។

យើងកត់សម្គាល់ឃើញថា បក្សទាំងមានច្រើនយ៉ាងនេះ តាមមហិច្ឆតា របស់ក្រុមវា និមួយៗ តែសំខាន់ ពួកវាគ្មានមហាជនគាំទ្រ ដូច្នេះទើបធ្វើអ្វីក៏មិនបាន ។

គ.- <u>អំពីមាគ៌ារបស់ បក្សក្បត់នេះ</u>:

ជាទូទៅ ពួកវានិយាយថា បក្សក្បត់នេះ ដើរតាម មាគ៌ាសេរី របស់ បក្សយួន ស្លាប់យួន ចោរយួន ជាគូបដិបក្ស ។

ចម្លើយ វើងគី ហៅ ខេត ដឹកជញ្ជូនផ្លូវទឹក របស់ជាការនៅស៊ូប៊ីញ៉ាក់ ថ្ងៃ 9.7.1977 បានសារភាព អំពីលក្ខន្តិកៈ បក្សក្បត់នេះថា ÷

1. ជនណាប្រឆាំង ប.ក.ក សកម្ម នឹងត្រូវបានបញ្ចូលជាបក្ខជន បក្សពលករកម្ពុជា
2. ទាហាន គីមីង់ថូ សេរីកា ដែលមានសកម្មភាពប្រឆាំង ប.ក.ក សកម្ម ក៏នឹងត្រូវបញ្ចូលជាបក្ខជន បក្សពលករកម្ពុជាដែរ ។

ឃ.- <u>អំពីមេដឹកនាំ របស់ បក្សក្បត់នេះ</u>:

①.- រហូតពេលកន្លងមក ពុំធ្លាប់មាន នរណា ណា និយាយច្បាស់ អំពីបញ្ហានេះទេ ។

②.- តែសមាសភាព ដឹកនាំ ជាន់ខ្ពស់របស់ បក្សនេះ ដែលត្រូវមានជីវិតរការ គាត់ខ្លួន 4 ស្លាប់ហើយ [redacted] មាន

1. ស៊ីង ស៊ុក មិញ ស្លាប់នៅប្រទេសយួន ឆ្នាំ 1973
2. ថែវ ហាស ចាប់ខ្លួនថ្ងៃ 25.9.1976
3. យ៉ាំ អតីតលេខាភាគឥសាន្ត ចាប់ខ្លួនថ្ងៃ 20.9.1976

00285392



ບສວີ
ບສສາ
ບສໃສ
ບສເລືອງ

4. កុយធួន ហៅ ឃួន អតីតលេខាភូមិភាគ 304 ចាប់ខ្លួនថ្ងៃ 25 មករា 1977
5. ននសួន ហៅ ជ័យ អតីតលេខាតំបន់25 ចាប់ខ្លួនថ្ងៃ 1. វិច្ឆិកា 1976
6. សួសនៅ ហៅ ឈូក អតីតលេខាតំបន់ 24 ចាប់ខ្លួនថ្ងៃ 28 សីហា 1976
7. ជ្រាសិទ្ធ ហៅ ដុង អតីតអនុលេខាភាគ 201 ចាប់ខ្លួន ធ្នូ 1976
8. សឿវ៉ាស៊ី ហៅ ឌឿន អតីត សមាជិកភាគ 304 ចាប់ខ្លួនថ្ងៃ 16 កុម្ភៈ 1977
9. ស ចាន ហៅ ស្រេង អតីត អនុលេខាភាគ កណ្ដាល ចាប់ខ្លួនថ្ងៃ 17 កុម្ភៈ 1977
10. ប៊ូផាត់ ហៅ ហង់ អតីតលេខាតំបន់ 103 ចាប់ខ្លួនថ្ងៃ មករា 1978
11. ស៊ិតឃីង ហៅ ទុំ អតីតលេខាតំបន់ 22 ចាប់ខ្លួនថ្ងៃ 30 មេសា 1977
12. ជាំផល់ ហៅ សុត អតីតលេខាតំបន់ 106 ចាប់ខ្លួនថ្ងៃ 21.2.77

ផ្ញើជូនៈ ពួកភាគមានខ្សែយ ប៉ុណ្ណោះ ប៉ុណ្ណឹង ហើយ ទៅលើបងៗ ខ្លះ ផ្សេងៗ
1. បង ភឹម
2. បង ញឹម
3. បង ស៊ុំ ជាដើម ។

ចប់ ម២១ 12/3/78